# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា
# ការិយាល័យផ្តល់ជំនួយពិសេស
# មជ្ឈមណ្ឌលអប់រំ

440 North Broad Street–2nd Floor
PHILADELPHIA, PENNSYLVANIA 19130-4015

**សេចក្តីប្រកាសអំពីការពិនិត្យឡើងវិញដោយមិនលម្អៀង នៃកម្មវិធី លីហ្គែ (LeGare) នៃឆ្នាំ២០១៥**

សិស្សានុសិស្សថ្នាក់ទី៨ ដែលមាន IEPs, 504 Plans ឬដែលកំពុងទទួលជំនួយសម្រាប់ សិស្សដែលត្រូវការរៀនភាសាអង់គ្លេស ហើយបានដាក់ពាក្យស្នើសុំចូលរៀន ប៉ុន្តែគេមិនទទួលឲ្យចូលរៀននៅ **វិទ្យាល័យទទួលសិស្សដែលមានលក្ខណៈសម្បត្តិពិសេស វិទ្យាល័យដែលទទួលសិស្សទូទាំងក្រុង** ឬ **កម្មវិធី CTE** នៅវិទ្យាល័យក្នុងតំបន់ដែលពួកគេបានដាក់ពាក្យស្នើសុំចូលរៀននោះ ប្រហែលជាអាចមានសិទ្ធិទទួលនូវការពិនិត្យឡើងវិញដោយមិនលម្អៀង នៃកម្មវិធី លីហ្គែ។

ការពិនិត្យឡើងវិញដោយមិនលម្អៀង នៃកម្មវិធី លីហ្គែ គឺជាការពិនិត្យលើកទីពីរ ដែលផ្តោតខ្លាំង ទៅលើសំណុំឯកសាររបស់សិស្ស (ឧ. សំណុំឯកសារនៃការសិក្សា សេចក្តីត្រូវការនៃជំនួយក្នុងការសិក្សា ។ល។) និងលក្ខណៈវិនិច្ឆ័យនៃការទទួលសិស្ស របស់វិទ្យាល័យដែលគេបានស្នើសុំចូលរៀន។ ការពិនិត្យឡើងវិញនេះត្រូវបានធ្វើឡើងដោយអ្នកឯកទេសផ្នែកអប់រំ និងអ្នកជំនាញផ្នែកកម្មវិធីសិក្សាភាសាចម្រុះ។

សិស្សានុសិស្សដែលមានសិទ្ធិ នឹងចាប់ផ្តើមទទួលលិខិតនេះនៅ **ថ្ងៃទី១៥ ខែ ឧសភា** ដែលមានការណែនាំអំពីវិធីស្នើសុំឲ្យមានការពិនិត្យឡើងវិញដោយមិនលម្អៀង នៃកម្មវិធី លីហ្គែ។ បើសិនជាសិស្សទទួលលិខិតនេះ វាជាការទទួលខុសត្រូវរបស់ ក្រុមគ្រួសារ/ អាណាព្យាបាល ដើម្បីធ្វើការស្នើសុំ។ សាលាមិនអាចធ្វើការស្នើសុំឲ្យសិស្សបានទេ។

សិស្សានុសិស្សដែលមិនបានទទួលលិខិតនេះ គ្មានសិទ្ធិទទួលការពិនិត្យឡើងវិញដោយមិនលម្អៀងបានឡើយ។ ឧទាហរណ៍នៃមូលហេតុដែលគ្មានសិទ្ធិនោះគឺ៖

១. សិស្សានុសិស្សដែលមិនរៀនថ្នាក់ទី៨ នឹងចូលរៀនថ្នាក់ទី៩
២. សិស្សានុសិស្សដែលគេទទួលជា បណ្តោះអាសន្ន/មានលក្ខខ័ណ្ឌ
៣. សិស្សានុសិស្សដែលមានឈ្មោះនៅក្នុងការចាប់ឆ្នោត ប៉ុន្តែឈ្មោះរបស់ពួកគេមិនបានជ្រើសរើសនៅពេលចាប់ឆ្នោត
៤. សិស្សានុសិស្សដែលមិនបានដាក់ពាក្យស្នើសុំចូលរៀននៅ សាលាទទួលសិស្សដែលមានលក្ខណៈសម្បត្តិពិសេស សាលាដែលទទួលសិស្សទូទាំងក្រុង ឬសាលាដែលមានលក្ខណៈវិនិច្ឆ័យដើម្បីទទួលសិស្ស (ឧ. កម្មវិធី CTE នៅវិទ្យាល័យក្នុងតំបន់)
៥. មាតាបិតាដែលបដិសេធនូវការយល់ព្រមទទួលសិស្សឲ្យចូលរៀននៅវិទ្យាល័យដែលខ្លួនបានជ្រើសរើស

ក្រុមអ្នកឯកទេសផ្នែកអប់រំ និងអ្នកជំនាញផ្នែកកម្មវិធីសិក្សាភាសាចម្រុះ នឹងពិនិត្យឡើងវិញនូវសំណុំឯកសាររបស់សិស្ស សម្រាប់សិស្សដែលបាន ស្នើសុំឲ្យមានការពិនិត្យឡើងវិញដោយមិនលម្អៀង។

- ក្រុមអ្នកពិនិត្យសាឡើងវិញនឹងសម្រេចចិត្តដោយយោងទៅលើការជួយសម្រួលទៅតាមសេចក្តីត្រូវការ នៅក្នុង IEP, 504 Plan ឬ កម្មវិធី ESOL របស់ពួកគេ ថាតើសិស្សនឹងទទួលជោគជ័យនៅសាលាដែលគេបានជ្រើសរើសឬអត់។
- ក្រុមអ្នកពិនិត្យសាឡើងវិញ ជាអ្នកធ្វើការសម្រេចជាចុងក្រោយ។

គេនឹងផ្តល់លិខិតជម្រាបពីស្ថានភាពចុងក្រោយបង្អស់ ជូន នៅថ្ងៃ ឬ មុនថ្ងៃ ទី១៩ ខែមិថុនា។

សូមទាក់ទងទៅអ្នកដែលមានឈ្មោះខាងក្រោមនេះ បើសិនមានសំណួរបន្ថែម៖

**សម្រាប់សិស្សានុសិស្សដែលមាន IEP's**

Dr. Alton Strange
២១៥-៤០០-៥៦៦៦
astrange@philasd.org

**សម្រាប់ សិស្សានុសិស្សដែលត្រូវការរៀនភាសាអង់គ្លេស (ELL) ឬ មានការវិនិច្ឆ័យពីរ (IEP & ELL)**

Loretta Hulmes
២១៥-៤០០-៤២៤០, រើសយកលេខ២
lhulmes@philasd.org

**សម្រាប់សិស្សានុសិស្សដែលមាន គម្រោងការ ១៨/៥០៤**

Dr. Naomi Housman
២១៥-៤០០-៦៨៧២
nghousman@philasd.org

**បើមានសំណួរជាទូទៅ ឬដើម្បីស្នើសុំការពិនិត្យឡើងវិញដោយមិនលម្អៀង**

លោកអ្នកអាចអ៊ីមែលទៅ៖ legare@philasd.org